ក្រុមហ៊ុន ឆៃ ជីងហៀង គ្រុប

CHHAY CHINGHEANG GROUP LTD

# ប្រវត្តិសកម្មភាពសង្ខេបរបស់ក្រុមហ៊ុន

## 有限公司的概况活动来历

## ២០២១ - ២០២២



Company Address: Building K1-Unit 5B, Mao Tse Tung Blvd, S/K Toul Tum Poung 2, Khan Chamkamon, Phnom Penh

# មាតិកា / 目录

ទំព័រ


1). តើកត្តាអ្វីខ្លះដែលធ្វើឱ្យក្រុមហ៊ុន ឆៃ ជីងហ៊ាងគ្រុប (CCHG) ជោគជ័យមកទល់សព្វថ្ងៃ? 2-4

如今Chhay Ching Heang集团（CCH 集团有限公司）取得成功的因素是什么?

2). តើហេតុអ្វីបានជាលោកអ្នកគួរជ្រើសរើស ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) ធ្វើជាដៃគូសហការពាណិជ្ជកម្ម? 5

为什么要选择Chhay Ching Heang集团（CCH 集团有限公司）作为商业伙伴?

3). ចក្ខុវិស័យ និងបេសកកម្មរបស់ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) យើងខ្ញុំ 6

公司的将来计划 和 公司的目的点

4). តើស្ថាប័នណាខ្លះជាសម្ព័ន្ធរបស់ ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd)? 6-11

Chhay Ching Heang集团（CCH Group Ltd）的子公司有哪些?

5). តើក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) ផ្តល់សេវាកម្មអ្វីខ្លះដល់អតិថិជន និងដៃគូពាណិជ្ជកម្ម? 11

Chhay Ching Heang集团（CCH 集团有限公司）为客户和商业伙伴提供哪些服务?

6). ការចូលរួមកិច្ចការងារសង្គម របស់ ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCHG) អស់រយៈពេលជាង២១ឆ្នាំកន្លងមកនេះ 12-15

过去的21年参与Chhay Ching Heang集团（CCHG）的社会工作

7). សារដ៏មានអត្ថន័យរបស់ លោកអគ្គនាយកក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) 15-16

董事长Chhay Ching Heang（CHH集团有限公司）的致辞

## 1. តើកត្តាអ្វីខ្លះដែលធ្វើឱ្យក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCHG) ជោគជ័យមកទល់សព្វថ្ងៃ?

### 如今Chhay Ching Heang集团（CCH 集团有限公司）取得成功的因素是什么?

ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) បានបង្កើតឡើងនៅកំឡុងឆ្នាំ២០០១គិតមកទល់បច្ចុប្បន្ននេះក្រុមហ៊ុនយើងដំណើរការរយៈពេល២១ឆ្នាំមានទីតាំងស្នាក់ការនៅក្នុងរាជធានីភ្នំពេញ និងមានបុគ្គលិកបម្រើការងារប្រមាណ១០០នាក់។

Chhay Ching Heang集团（CCH 集团有限公司）成立于2001年。到现在为止，我们公司已经营了21年，总部位于金边，拥有约100人的员工。

តម្លៃស្នូលនៃការងាររបស់ពួកយើង គឺតែងតែគិតដល់ "គុណភាព" និង "ការពេញចិត្តរបស់អតិថិជន"។ ដូច្នេះហើយទើប រយៈពេលជាង២១ឆ្នាំកន្លងមកនេះ រាប់គិតចាប់តាំងពីការបង្កើតក្រុមហ៊ុនក្នុងឆ្នាំ ២០០១ មកក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) បានកសាងកេរ្តិ៍ឈ្មោះដ៏រឹងមាំនៅទូទាំងប្រទេសកម្ពុជា និងបានបង្កើតភាពជាដៃគូរដ៏ស្មោះត្រង់ជាមួយដៃគូពាណិជ្ជករ ក៏ដូចជាអ្នកវិនិយោគជាច្រើនទាំងក្នុង និងក្រៅស្រុក ព្រមទាំងទទួលបានទំនុកចិត្តពីអតិថិជន។ ភាពជោគជ័យរបស់យើងគឺដោយសារតែការខិតខំប្រឹងប្រែងប្រកបដោយចក្ខុវិស័យ និងការតាំងចិត្តខ្ពស់របស់ប្រមុខថ្នាក់ដឹកនាំ ក៏ដូចជាការប្តេជ្ញាចិត្តរបស់បុគ្គលិកជាង100នាក់របស់យើងដែលធ្វើការក្រោមក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) កិច្ចសហការដ៏រឹងមាំរវាងយើង និងអ្នកផ្គត់ផ្គង់/ សហគ្រាសផលិតផ្សេងៗរបស់យើង ការគាំទ្រពីស្ថាប័នហិរញ្ញវត្ថុ ការជឿទុកចិត្ត និងការគាំទ្រដ៏បិតថេរដែលយើងទទួលបានពីអតិថិជនរបស់យើង។



我们工作的核心是“质量”以及“客户的满意”。因此，自2001年公司成立21年多以来，Chhay Ching Heang集团（CCH 集团有限公司）在柬埔寨建立了良好的声誉并建立了忠诚的合作伙伴关系，赢得国内外商业伙伴以及众多投资者合作的信任。我们的成功是归于我们领导的远见的努力和献身，在Chhay Ching Heang集团（CCH集团有限公司）工作的100多名员工的努力，以及供应商/各种制造企业之间的紧密合作、金融机构的支持、信任以及我们从忠实客户那里获得的持久支持。

ក្រៅពីនេះក្រុមហ៊ុនតែងតែផ្តល់ជូននូវផលិតផល ឬសេវាកម្មដ៏ល្អបំពេញតម្រូវការជូនអតិថិជនដោយអនុទ្យោមតាមគោលការណ៍របស់ក្រុមហ៊ុន ជាមួយនឹងកិច្ចសន្យាច្បាស់លាស់រវាងដៃគូរសហការណ៍។ បន្ថែមពីនេះការរៀបចំហេដ្ឋារចនាសម្ព័ន្ធការងារក្នុងក្រុមហ៊ុន ក៏ជាកត្តាសំខាន់ដែលធ្វើឱ្យក្រុមហ៊ុនជោគជ័យផងដែរ។ ជាក់ស្តែង ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) បានរៀបចំហេដ្ឋារចនាសម្ព័ន្ធការងារស្តង់ដានិងត្រឹមត្រូវ ដោយក្រុមថ្នាក់ដឹកនាំជាន់ខ្ពស់ខាងលើ គឺជាថ្នាក់ដឹកនាំប្រកបដោយឆន្ទៈខ្ពស់ បទពិសោធន៍យូរឆ្នាំ និងគ្រប់គ្រងដឹកនាំក្រុមហ៊ុនប្រកបដោយរលូន និងជោគជ័យជានិច្ច។ ជាមួយគ្នានេះ បុគ្គលិកគ្រប់ផ្នែកសុទ្ធសឹងតែមានឆន្ទៈខ្ពស់ចំពោះការងារ "ធ្វើការមិនប្រកាន់ពេលវេលា ឬមិនឿយណាយនឹងការងារចំពោះមុខ " ដើម្បីធានាថា ការផ្តល់ជូនផលិតផល និងសេវាកម្មរបស់យើងប្រកបដោយគុណភាព វិជ្ជាជីវៈ សុចរិតភាព និងភាពស្មោះត្រង់ ក្នុងទិសដៅបំពេញសេចក្តីត្រូវការរបស់អតិថិជន និងដៃគូរវិនិយោគ។

此外，公司始终根据公司的政策和合作伙伴之间的明确合同，提供良好的产品或服务，以满足客户的需求。另外，公司工作基础设施的组织也是我们公司成功的重要因素。事实上，Chhay Ching Heang集团（CCH集团有限公司）有高度的积极性，经验丰富的高管团队，能够顺利成功建立了一个标准和准确的工作基础设施。然而，各部门的员工都非常积极地工作“工作不看时间或不厌前面的工作”之为了保证公司能够以优质、专业、正直及诚实的方式提供我们的产品和服务，以满足客户和投资伙伴的需求。

សារភ្ជាប់ជាមួយភាពជោគជ័យនេះ លោកអគ្គនាយក ឆៃ ជីងហ៊ាង បានលើកឡើងថា «ក្នុងនាមខ្ញុំជាអគ្គនាយកក្រុមហ៊ុន សូមថ្លែងអំណរអរគុណដ៏ជ្រាលជ្រៅពីសំណាក់អតិថិជន ដៃគូរពាណិជ្ជកម្ម និងបុគ្គលិកទាំងអស់ ដែលបានខិតខំពុះពារបន្តការងារប្រកបដោយប្រសិទ្ធិភាព និងគុណធម៌។ ជាមួយគ្នានេះដែរនេះគឺជាកិត្តិយសរបស់បុគ្គលិកទាំងអស់នៅក្នុង ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) ដែលបានធ្វើការជាមួយដៃគូអាជីវកម្ម និងតែងបង្កើតការជឿទុកចិត្តសម្រាប់ពួកយើងតាមរយៈការសហការ និងលទ្ធផលជាផ្លែផ្ការបស់យើង។ហើយយើងត្រៀមខ្លួនជាស្រេច ដើម្បីជួយអ្នកក្នុងការខិតខំប្រឹងប្រែងនាពេលអនាគត ហើយយើងកំពុងទន្ទឹងរង់ចាំភាពជាដៃគូបន្តបន្ទាប់របស់យើង ខណៈដែលយើងកំពុងបន្តពង្រីកអាជីវកម្មរបស់ក្រុមហ៊ុន។ ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) គឺព្យាយាមពង្រីកខ្លួននៅក្នុងទីផ្សារប្រកួតប្រជែងទាំងក្នុង និងក្រៅស្រុកហើយបង្កើនភាពជឿជាក់ដល់ដៃគូពាណិជ្ជកម្មក្រៅស្រុកមកអភិវឌ្ឍក្នុងព្រះរាជាណាចក្រកម្ពុជា។»៕

关于此次成功，董事长Chhay Ching Heang表示：“作为公司的董事长，我向所有辛勤工作的客户、商业伙伴以及员工深深地表示感谢。然而，这是Chhay Ching Heang集团所有员工地荣幸，能够与业务伙伴合作和卓有成效的成果，始终为我们建立信任。我们已准备好在您未来的工作中为您提供帮助，我们期待在我们继续扩大业务的同时继续建立合作的关系。Chhay Ching Heang集团CCH集团有限公司)正在国内外努力扩张市场，并增加外国商业伙伴的信任能够来柬埔寨王国发展。



**CHHAY CHING HEANG** 先生
CHHAY CHINGHEANG集团 有限公司董事长。

## 2. តើហេតុអ្វីបានជាលោកអ្នកគួរជ្រើសរើស ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) ធ្វើជាដៃគូសហការពាណិជ្ជកម្ម?

យោងតាមបទពិសោធន៍ការងារអស់រយៈពេលជាង២១ឆ្នាំ ចាប់តាំងពីការបង្កើតក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) ក្នុងឆ្នាំ២០០១មកទល់សព្វថ្ងៃនេះ ពួកយើងទទួលបានទំនុកចិត្តខ្ពស់ពីអតិថិជនទាំងក្នុង និងក្រៅស្រុក រួមទាំងការគាំទ្រដ៏ខ្លង់ខ្ពស់ពីរាជរដ្ឋាភិបាល គឺពួកយើងតែងតែយកចិត្តទុកដាក់ទៅលើសមិទ្ធផលការងារដើម្បីធានាថា ការផ្តល់ជូនផលិតផល និងសេវាកម្មរបស់យើង ប្រកបដោយគុណភាព វិជ្ជាជីវៈ សុចរិតភាព និងភាពស្មោះត្រង់ ក្នុងទិសដៅបំពេញសេចក្តីត្រូវការរបស់អតិថិជន និងដៃគូវិនិយោគ ដូច្នេះហើយទើបពួកយើងមានឱកាសសម្រេចបាននូវភាពជោគជ័យលើគម្រោងជាច្រើនជូនអតិថិជន និងដៃគូសហការជាច្រើន ។

**为什么要选择Chhay Ching Heang集团（CCH 集团有限公司）作为商业伙伴?**

自2001年Chhay Ching Heang集团（CCH 集团有限公司）成立至今，已经有21多年的经验，也赢得了国内外客户的信任，包括王国政府的高度支持，是因为我们始终注重绩效，保证我们的产品和服务以质量、专业、诚信和诚实，能够满足客户和投资伙伴的需求。因此，我们有机会为更多多客户和合作伙伴在许多项目中取得成功。



## 3. ចក្ខុវិស័យ និងបេសកកម្មរបស់ក្រុមហ៊ុន / 公司的将来计划 和 公司的目的点

ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) មានចក្ខុវិស័យ «ពង្រីកវត្តមានរបស់យើង នៅក្នុងវិស័យសេដ្ឋកិច្ចផ្សេងៗដើម្បីបង្កើតឱកាសអាជីវកម្មថ្មីៗ ក្នុងការទាក់ទាញអតិថិជនថ្មីៗទាំងក្នុង និងក្រៅស្រុកក៏ដូចជាកសាងផលប័ត្រម៉ាកយីហោលំដាប់ទីមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។»

在21多年以来的成功，Chhay Ching Heang集团得到了海内外客户的高度信任，包括皇家政府的高度支持，我们始终注重绩效，保证我们的产品和服务以质量、专业、诚信和诚实，能够满足客户和投资伙伴的需求，这是我们清晰愿景的回应。

សារភ្ជាប់ជាមួយនឹងចក្ខុវិស័យនេះដែរ «ពួកយើងតែងតែគោរពផ្តល់តម្លៃ និងពង្រីកទំនាក់ទំនងយ៉ាងទូលំទូលាយជាមួយដៃគូរពាណិជ្ជកម្មទាំងអស់។ ពួកយើងលើកកម្ពស់ដល់ដៃគូសហការដើម្បីពង្រីក និងពង្រឹងការងារប្រកបដោយប្រសិទ្ធិភាព ព្រមទាំងលើកទឹកចិត្តចំពោះដៃគូសហការ ដែលតែងតែចែករំលែកគំនិតអភិវឌ្ឍន៍ល្អៗ ហើយពួកយើងមានការពេញចិត្តស្វាគមន៍រាល់ទស្សនៈវិស័យ និងជំនាញការផ្សេងៗគ្នាផងដែរ។»

Chhay Ching Heang集团（CCH Group Ltd）的愿景是“在柬埔寨王国扩大各个经济领域的影响力，创造新的商机，吸引国内外新客户，以及创造一顶流的品牌”。
与愿景所表示有关的信息是：“我们始终尊重、并扩大我们与商业伙伴的关系。我们鼓励合作伙伴扩大并加强工作的效力，也鼓励我们的合作伙伴分享良好的发展理念

## 4. តើស្ថាប័នណាខ្លះជាសម្ព័ន្ធរបស់ ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd)?

**Chhay Ching Heang集团（CCH Group Ltd）的子公司有哪些?**

ទន្ទឹមនឹងភាពជោគជ័យនេះផងដែរ ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) បានពង្រឹងនិងពង្រីកសក្តានុពលរបស់ខ្លួនកាន់តែធំទូលាយ និងរឹងមាំទូទាំងប្រទេសកម្ពុជា ដោយបានបង្កើតឱ្យមានសម្ព័ន្ធក្រុមហ៊ុនជាច្រើន (បុត្រសម្ព័ន្ធចំនួន ១៧ ក្រុមហ៊ុន) ដើម្បីរួមគ្នាក្នុងគោលដៅឆ្ពោះទៅរកភាពរីកចម្រើនជាមួយគ្នា។

随着这一成功，Chhay Ching Heang集团（CCH Group Ltd）通过建立几家子公司（17家子公司）团结起来，增强并扩大了其在柬埔寨各地扩张和壮大的潜力，共同在目标中共同进步。

## 2009

### CHHAY CHINGHEANG IMPORT EXPORT CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ សណ្ឋាគារ និងរមណីយដ្ឋាន

主要经营活动：  酒店和度假村

## 2014

### TOP TEAM INTERNATIONAL DEVELOPMENT CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ ការដ្ឋាន កិន វាយថ្មដើម្បីផ្គត់ផ្គង់វិស័យសំណង់

主要经营活动：  石磨现场

## 2015

### ANGKOR MEAS (CAMPUCHEA) CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ ៖ អចលនទ្រព្យ (ការអភិវឌ្ឍន៍លំនៅដ្ឋាន)

主要经营活动：房地产 (住宅开发)

## 2017

### ASIAN ORIENTAL BUILDING (CAMBODIA) CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ អចលនទ្រព្យ (ការអភិវឌ្ឍន៍លំនៅដ្ឋាន)

主要经营活动：  房地产 (住宅开发)

2017

### H.Y CHENG INVESTMENT CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ នាំចូលនាំចេញ (ផលិតផលកសិកម្ម)

主要经营活动： 进出口（农产品）

2017

### WORLDWIDE ECO RESORT CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ សណ្ឋាគារ និងរមណីយដ្ឋាន

主要经营活动：酒店和度假村

2017

### ZHONG NAN BO YU (CAMBODIA) AUTOMOBILE MANUFACTURING CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ នាំចូល នាំចេញ (គ្រឿងបន្លាស់រថយន្ត)

主要经营活动： 进出口 (汽车备件)

2018

### BEIJING (CAMBODIA) COASTAL INTERNATIONAL INVESTMENT CO.,LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ អចលនទ្រព្យ (ទិញ លក់ និងជួល)

主要经营活动： 房地产(购买、销售和租赁)

2018

**Y FI CO., LTD.**

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ សំណង់ (អគារ)

主要经营活动：建筑（城楼）

2019

**ROCK MINERALOGY DEVELOPMENT CO., LTD.**

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ រោងចក្រស៊ីម៉ង់ត៍

主要经营活动： 水泥工厂

2019

**GOLDEN LOCKS (CAMBODIA) CO., LTD.**

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ នាំចូលនាំចេញ (សោ) និង (ជីកសិកម្ម)

主要经营活动：进出口锁和农肥

2019

**K.P CEMENT INDUSTRY CO., LTD.**

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ សេវាកម្មរុករករ៉ែថ្មកំបោរ

主要经营活动：石灰石开采勘探

2019

## ZHONG TAO BOHAN (CAMBODIA) REAL ESTATE DEVELOPMENT CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ អចលនទ្រព្យ (ទិញ លក់ និងជួល)

主要经营活动：房地产(购买、销售和租赁)

2020

## BLUE VALLEY MANAGEMENT CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ បង្កើតតំបន់សេដ្ឋកិច្ចពិសេស

主要经营活动： 经济特区

2020

## ZHONG TIAN HUA YU INTERNATIONAL DEVELOPMENT CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ អចលនទ្រព្យ (ការអភិវឌ្ឍន៍លំនៅដ្ឋាន)

主要经营活动： 房地产 (住宅开发)

2020

## SAN HEANG (CAMBODIA) IMPORT EXPORT CO., LTD.

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ អភិវឌ្ឍន៍លើវិស័យកសិកម្ម ទិញ លក់ ឬជួល

主要经营活动：发展农业产业，买卖、出租。

**2021**

**CCHG COMMODITY CO., LTD.**

សកម្មភាពអាជីវកម្មចម្បង(គឺ)៖ នាំចូល នាំចេញ (អាហារ និងភេសជ្ជៈ)
主要经营活动：进出口（食品和饮料）

## 5. តើក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) ផ្តល់សេវាកម្មអ្វីខ្លះដល់អតិថិជន និងដៃគូពាណិជ្ជកម្ម?
## Chhay Ching Heang集团（CCH 集团有限公司）为客户和商业伙伴提供哪些服务?

បច្ចុប្បន្ននេះ ពួកយើងបានផ្តល់ជូនសេវាកម្មជាច្រើនដល់អតិថិជន និងដៃគូពាណិជ្ជកម្ម ដូចជា៖

我们已经为客户和商业伙伴提供了许多服务。

1. អចលនទ្រព្យ និងអចលនវត្ថុ 房地产和房地产
2. អភិវឌ្ឍន៍ខុនដូ និងអាផាតមិន 公寓开发
3. វិនិយោគ និងអភិវឌ្ឍតំបន់ទេសចរណ៍ 开发及投资旅游景点
4. អាហរ័ណ នីហរ័ណ 进口和出口
5. ក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្ម 广告代理服务
6. សេវាកម្មដឹកជញ្ជូន និងបញ្ញើតាមផ្លូវ អាកាស គោក និងទឹក 空、海、陆运输服务
7. សេវាកម្មសំណង់ 建筑服务
8. ជំនាញស្វែងរកការងារ និងផ្គត់ផ្គង់បុគ្គលិកគ្រប់ផ្នែក 各种部门的招聘及供应人员的专家
9. វិស័យឧស្សាហកម្ម 产业部门
10. វិស័យកសិកម្ម 农业，水稻、甘蔗 坚果
11. វិស័យគ្រឹះស្ថានហិរញ្ញវត្ថុ 金融机构行业

## 6. ការចូលរួមកិច្ចការងារសង្គម របស់ ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) អស់រយៈពេលជាង ២១ ឆ្នាំកន្លងមកនេះ

យោងតាមសារដ៏មានអត្ថន័យជ្រាលជ្រៅ និងឆន្ទៈដ៏ខ្ពង់ខ្ពស់របស់លោកអគ្គនាយក **ឆៃ ជីងហ៊ាង** ដែលតែងតែយកចិត្តទុកដាក់ដល់ការចូលរួមកិច្ចការងារសង្គម ជាមួយការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីគាំទ្រ និងលើកកម្ពស់ដល់ការអភិវឌ្ឍន៍សង្គមជាតិ ក៏ដូចជាការរស់នៅរបស់ប្រជាជនកម្ពុជាឱ្យកាន់តែប្រសើរឡើង ទើបក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd) បានបង្កើតកម្មវិធីទំនួលខុសត្រូវសង្គមជាច្រើនដូចខាងក្រោម៖

**过去的21年参与Chhay Ching Heang集团（CCH 集团有限公司）的社会工作：**

根据董事长Chhay Ching Heang的深意和崇高意志的讯息，他始终重视参与社会工作，配合支持皇家政府以及促进社会和生活的发展。因此Chhay Ching Heang集团（CCH集团有限公司）制定了多项社会责任计划，如下所示：



- នាយកប្រតិបត្តិក្រុមហ៊ុន K.P CEMENT INDUSTRY CO.,LTDយើងខ្ញុំបានឧបត្ថម្ភអង្ករចំនួន 50តោនជូនអភិបាលខេត្តកំពង់ស្ពឺ។
- K.P CEMENT INDUSTRY CO., LTD的首席执行官向磅士卑省长捐赠了50吨大米。



- លោកអគ្គនាយក និងជាស្ថាបនិកក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប បានឧបត្ថម្ភក្រមាខ្មែរ 1000 ក្រមា ដល់ប្រជាជនកម្ពុជាតាមរយៈឯកឧត្តម ដួង តារា។
- Chhay Ching Heang 的董事长兼创始人通过Duong Dara阁下向柬埔寨人民捐赠了1000个柬埔寨的丝绸。



• កាលពីថ្ងៃទី 24 សីហា 2020 លោកអគ្គនាយកក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប និងលោកស្រីអគ្គនាយិការបានយកអំណោយផ្ទាល់ខ្លួនជាអង្ករ ទឹកបរិសុទ្ធ និងគ្រឿងទេសផ្សេងៗទៀតចែកជូនដល់លោកយាយលោកតាដែលជាជនចាស់ជរា និងពូៗជាជនពិការនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

• 在2020年08月24日，Chhay Ching Heang集团的董事长，Chhay Ching Heang先生和夫人带了个人的赠品如大米、矿泉水和其他香料捐给Tbong Khmum省Memot区的老人以及残疾人。



• លោក ឆៃ ជីងហ៊ាង អគ្គនាយកក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប និងលោកស្រីអគ្គនាយិការបានឧបត្ថម្ភបង្គោលភ្លើង និងអំពូលភ្លើងសូឡា ចំនួន70 ដល់ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

• Chhay Ching Heang董事长，Chhay Ching Heang 先生和夫人也曾向Tbong Khmum省Memot区捐赠了70根灯杆和太阳能灯。



• លោក ឆៃ ជីងហ៊ាង អគ្គនាយកក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប និងលោកស្រីអគ្គនាយិការបានឧបត្ថម្ភម៉ាស៊ីនវាស់កម្តៅ ចំនួន 170 គ្រឿងជូនដល់រដ្ឋបាលខេត្តព្រះសីហនុ។

• Chhay Ching Heang先生，Chhay Ching Heang集团的董事长和夫人也向西哈努克省政府捐赠了170个温度计。



• ថ្ងៃទី 25 ខែ មេសា ឆ្នាំ 2019 លោកអគ្គនាយក ឆៃ ជីងហ៊ាង និងលោកស្រីអគ្គនាយិការ បានចូលរួមបរិច្ចាកនូវថវិការផ្ទាល់ខ្លួនចំនួន 5100 ដុល្លារ ដល់មន្ទីរពេទ្យគន្ធបុប្ផា។

• 2019 年 4 月 25 日：董事长Chhay Ching Heang 和董事长夫人用个人的款项向 Kantha Bopha 医院捐的 5,100 美元。



• ថ្ងៃទី 01 ខែសីហា ឆ្នាំ 2019៖ លោកស្រីអគ្គនាយិការ តំណាងអោយលោកអគ្គនាយកឆៃ ជីងហ៊ាង បានផ្តល់ផ្ទះមួយខ្នងទំហំ 4មx6ម ដល់ប្តីប្រពន្ធដែលជួបការខ្វះខាតនៅស្រុកពាមជីកង ខេត្តកំពង់ចាម។

• 2019年8月1日：董事长夫人，代表董事长Chhay Ching Heang向磅湛省Peam Chi Kang区的一对贫困夫妇捐赠了一座4mx6m的房子。



• ថ្ងៃទី 20 កក្កដា 2020៖ លោកអគ្គនាយក និងលោកស្រីអគ្គនាយិការ របស់ក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប បានអញ្ជើញទៅមន្ទីពេទ្យ គន្ធបុប្ផា សាខាវត្តភ្នំ រាជធានីភ្នំពេញ ដើម្បីចូលរួមបរិច្ចាកនូវ ថវិការផ្ទាល់ខ្លួនចំនួន 5100 ដុល្លារ ។

• 2020年7月20日，Chhay Ching Heang 集团的董事长和夫人去金边市，Wat Phnom 分区的Kantha Bopha医院捐赠5100美元。



- ថ្ងៃទី 03 ខែតុលា ឆ្នាំ 2019៖ លោកអគ្គនាយក ឆៃ ជីងហ៊ាង និងលោកស្រីអគ្គនាយិការបានចូលរួមបរិច្ចាកនូវថវិការចំនួន 6,168 ដុល្លារ ដល់មន្ទីរពេទ្យគន្ធបុប្ផាម្តងទៀត។
- 2019 年 10 月 3 日：董事长Chhay Ching Heang 和夫人再次向 Kantha Bopha 医院捐款 6,168 美元。

## 7. សារដ៏មានអត្ថន័យរបស់ លោកអគ្គនាយកក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd)

### 董事长Chhay Ching Heang（CHH集团有限公司）的致辞

ក្រោមការដឹកនាំដ៏ឆ្លាតវៃ ប៉ិនប្រសព្វ និងឆ្នើម  របស់លោកអគ្គនាយក **ឆៃ ជីងហ៊ាង** បានធ្វើឱ្យក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប (CCH Group Ltd)  ទទួលបានភាពជោគជ័យយ៉ាងធំធេង  និងកសាងកេរ្តិ៍ឈ្មោះដ៏រឹងមាំនៅទូទាំងប្រទេសកម្ពុជា និងបានបង្កើតភាពជាដៃគូដ៏ស្មោះត្រង់  និងទំនុកចិត្តជាមួយដៃគូជាច្រើនទាំងក្នុង និងក្រៅស្រុក។

在董事长Chhay Ching Heang（CHH集团有限公司）的英明、才华横溢以及精益的领导之下，Chhay Ching Heang集团（CCH Group Ltd）取得了巨大的成功，并在柬埔寨各地建立了良好的声誉，与众多国内国外的合作伙伴的忠诚并值得信赖的合作伙伴。

- ខាងក្រោមនេះជាខ្លឹមសារដែលលោក អគ្គនាយកបានចែករំលែក៖
- 以下是董事长分享的内容：

ក្នុងភាពជោគជ័យយ៉ាងធំធេងអស់រយៈពេលជាង ២១ឆ្នាំ រាប់ចាប់តាំងពីការបង្កើតក្រុមហ៊ុនក្នុងឆ្នាំ ២០០១ មកនេះ ខ្ញុំតែងតែសង្កត់ធ្ងន់ថា «តម្លៃស្នូលរបស់ក្រុមហ៊ុនយើងគឺជា "គុណភាព" និង "ការពេញចិត្តរបស់អតិថិជន"។ ក្រុមការងាររបស់យើងទាំងអស់បានខិតខំប្រឹងប្រែងដើម្បីធានាថាយើងផ្តល់ជូននូវ ផលិតផល និងសេវាកម្មប្រកបដោយគុណភាពវិជ្ជាជីវៈ សុចរិតភាព និងភាពស្មោះត្រង់។ លើសពីនេះនៅ CCH Group Ltd វាក៏ជាអាទិភាពកំពូលរបស់យើងផងដែរក្នុងការបង្កើន ការត្រឡប់មកវិញលើការវិនិយោគ និងប្រាក់ចំណេញរបស់អតិថិជនក៏ដូចជាដៃគូអាជីវកម្មរបស់យើង។



自2001年公司成立以来，在21多年的巨大成功中，我一直强调“我们的核心价值观是“质量”和“客户满意度”。我们的团队都在努力地工作，为了确保能够提供优质、专业、诚信和正直的产品和服务给客户。此外，在 CCH Group Ltd，提高客户和业务合作伙伴的投资回报和利润也是我们最重要的任务。

អស់រយៈពេលជាងពីរទសវត្សរ៍នៃប្រតិបត្តិការក្រុមហ៊ុន ឆៃ ជីងហ៊ាង គ្រុប ( CCH Group Ltd) ខ្ញុំសូមសម្តែងការកោតសរសើរចំពោះការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់បុគ្គលិកជាង 100នាក់របស់យើង និងកិច្ចសហការដ៏រឹងមាំរវាងយើងនិងអ្នកផ្គត់ផ្គង់ /សហគ្រាសផលិតផ្សេងៗ ការគាំទ្រពីស្ថាប័នហិរញ្ញវត្ថុ ការជឿទុកចិត្ត និងការគាំទ្រដ៏បិតថេរដែលយើងបានទទួលពីអតិថិជនស្មោះត្រង់របស់យើង។

在这二十年的经营过程中，Chhay Ching Heang集团（CCH集团有限公司）在此表示感谢100多名员工的辛勤工作和敬业精神，以及供应商/企业的大力合作，金融机构支持，信任，以及我们忠实客户的支持。

ក្នុងនាមខ្ញុំជាស្ថាបនិក និងអ្នកគ្រប់គ្រងទាំងអស់នៅ CCH Group Ltd ពិតជាមានកិត្តិយសដែលបានសហការធ្វើការជាមួយដៃគូអាជីវកម្មរបស់យើងកន្លងមក ដែលតែងតែបង្កើនការជឿទុកចិត្តតាមរយៈកិច្ចសហការ និងការងារផ្សេងៗ។ យើងខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីជួយលោកអ្នកក្នុងការខិតខំប្រឹងប្រែងនាពេលអនាគតរបស់លោកអ្នក ហើយយើងកំពុងទន្ទឹងរង់ចាំភាពជាដៃគូបន្ទាប់របស់យើង ខណៈដែលយើងកំពុងបន្តពង្រីកអាជីវកម្មឥតឈប់ឈរ។» ៕

作为 CCH Group Ltd 的创始人和所有管理人员，我们很荣幸与我们的商业合作伙伴一起工作，并通过协作以及其他业务来建立信任。我们已做好准备能在您未来的工作中为您提供协助，我们也期待着能跟下一个合作伙伴建立关系，同时也将继续扩大我们的业务。

ដោយក្តីគោរពដ៏កក់ក្តៅ
**ឆៃ ជីងហ៊ាង**
ស្ថាបនិក និងជាអគ្គនាយកគ្រប់គ្រងទូទៅ CCH GROUP LTD

表示非常感谢!

**CHHAY CHING HEANG** 先生

CHHAY CHINGHEANG集团 有限公司董事长。

សូមអរគុណ!

谢谢！